# មហាឧបាសិកា សីលធម៌ និងអំពើជាកុសល របស់ស្ត្រីនៅប្រទេសកម្ពុជា ជាសម័យកណ្ដាល

ដោយ ទ្រូឌី ចេកុប្សិន

*សំណួរអំពីភាពជាមហាក្សត្រ* បានបង្កើតឲ្យមានការពិចារណាមួយ សម្រាប់ក្រុមអ្នកប្រាជ្ញដែលសិក្សាប្រវត្តិសាស្ត្រខ្មែរនៅគ្រិស្តសតវត្សរ៍ទី ២០ នេះរួចស្រេចអស់ទៅហើយ ។ ប៉ុន្តែ ចំណាប់អារម្មណ៍ស្រដៀងគ្នានេះទៅលើភាពជាមហាក្សត្រិយានីឬជាព្រះមហេសី ហាក់ដូចជាមិនទាន់មានគេយកមកសិក្សានៅឡើយទេ ។ ការណ៍អស់ទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីការលុបបំបាត់ចោលនូវតួនាទីរបស់ស្ត្រីពីសំណៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។ ទើបតែពេលឥឡូវនេះទេ ដែលតួនាទីស្ត្រីពីអតីតកាលបានបញ្ចេញសម្លេងនៅក្នុងប្រវត្តិសាស្ត្រឡើងវិញ ។ ប៉ុន្តែ បើទោះជាយ៉ាងណាក្តី ក៏ផ្នែកជាច្រើននៃប្រវត្តិសាស្ត្របានបង្ហាញថា ស្ត្រីខ្មែរ គឺជាអ្នកតំណាងឲ្យជនរងគ្រោះ ដែលបង្កឡើងដោយសាសនា និងប្រព័ន្ធអំណាចបេត្តយ្យកា (អំណាចធ្លាក់ទៅលើបិតា) ដែលមិនឲ្យតម្លៃលើស្ត្រី ។ ហើយបញ្ហាទាំងនេះ យើងអាចមើលឃើញច្បាស់ជាងគេទាំងអស់នៅក្នុងប្រវត្តិនៃសម័យកណ្ដាលរបស់ប្រទេសកម្ពុជា (គ.ស. ១៤៣១-១៨៦០)[១] ។ ប៉ុន្តែ ស្របពេលជាមួយគ្នានេះដែរ ប្រភពឯកសារទាំងឡាយដែលជាសំអាងនៅសម័យកាលនេះ ក៏នៅតែមានតិចតួច ហើយសម័យកាលកណ្ដាលនេះទៀតសោត ក៏មានរយៈពេលវែងលើសលប់ ឯការអង្កេតរបស់ក្រុមជនបរទេសក៏កម្រមានដែរ ហើយបើទោះបីជាពេលនោះ ប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ បានចាប់ផ្តើមរំកិលខ្លួនចូលទៅក្នុងយុគថ្មីមួយទៀត ដែលគេហៅថា «ដើមនៃយុគទំនើប» នោះក៏ដោយ ក៏ប្រវត្តិនៃប្រទេសកម្ពុជានៅតែស្រពេចស្រពិល និងមិនសូវលេចឡើងនៅក្នុងកំណត់ហេតុរបស់ពួកពាណិជ្ជករ និងបព្វជិតផ្សព្វផ្សាយគ្រិស្តសាសនាជាច្រើននោះទេ ដែលជាហេតុធ្វើឲ្យក្រុមប្រវត្តិវិទូត្រូវពឹងផ្អែកទៅលើឯកសារដែលនៅរាយប៉ាយ និងមិនប្រក្រតី និងឯកសារមួយចំនួនតូចទៀត ទាក់ទងទៅនឹងអក្សរសាស្ត្របុរាណ ដែលបំពេញបន្ថែមដោយប្រភពសិលាចារឹកមួយចំនួនទៀត ដើម្បីធ្វើការវិភាគលើប្រវត្តិសាស្ត្រនៃប្រទេសប្រទេសកម្ពុជានាសម័យកណ្ដាល ។ ប៉ុន្តែ បើពឹងផ្អែកទៅលើប្រភពឯកសារទាំងនេះខ្លាំងពេក ក៏អាចនាំឲ្យមានការប្រាសចាកពីសេចក្ដីពិតផងដែរ ។ បន្ថែមលើបញ្ហាដែលបានរៀបរាប់ហើយមកនេះ ភាពលំអៀងនៃក្រុមប្រវត្តិវិទូនៅសតវត្សរ៍ទី ១៩ ក៏បានរាំងខ្ទប់ប្រភពឯកសារទាំងនោះ មិនឲ្យមានការបកស្រាយតាមទស្សនៈត្រឹមត្រូវ អំពី «ភេទភាវៈ» (យេនឌ័រ) ផងដែរ ។ ប៉ុន្តែ បើពិនិត្យទៅលើគោលនៃព្រះធម៌វិញនោះ យើងនឹងឃើញនូវតួនាទីយ៉ាងសំខាន់របស់ស្ត្រីក្នុងពុទ្ធសាសនាខ្មែរ វិសេសលើសពីការបង្ហាញនៅក្នុងស្នាដៃមុនៗ ទៅទៀត ដែលបង្ហាញឲ្យឃើញថាការចូលមកដល់នៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មិនបានធ្វើឲ្យបាត់បង់ឋានៈរបស់ស្ត្រីនៅក្នុងសង្គមទេ ហើយក៏មិនបានច្រានចោលពួកគេមិនឲ្យចូលរួមក្នុងការប្រតិបត្តិសាសនានោះដែរ ។ ជាឧទាហរណ៍

ប្រជាប្រិយភាពរបស់នាងគង្ហីងព្រះធរណី ដែលជាទេពធីតាតំណាងឲ្យផែនដី ដែលបានចូលខ្លួនមកជួយព្រះពុទ្ធអង្គក្នុងការផ្ចាញ់មារ ដោយច្បូតសក់ព្រះនាងឲ្យចេញជាទឹកនិងក្រពើនោះ[២] ជាភស្តុតាងយ៉ាងច្បាស់ក្នុងការបង្ហាញអំពីតួនាទីនិងស្វ័យភាពរបស់ស្ត្រី នៅក្នុងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជានាសម័យកាលនោះ ។ ដូច្នេះហើយ តួនាទីរបស់ព្រះមហេសីឬព្រះវររាជមាតា ដែលជាពុទ្ធសាសនិកក្នុងការថែរក្សា និងការកាន់យកព្រះធម៌ សមនឹងទទួលបាននូវការវិភាគយ៉ាងជិតដល់បំផុត ។

គំរូសម្រាប់ភាពជាព្រះមហេសី យើងបានឃើញមានមកតាំងតែពីកំឡុងពេលដំបូងក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាម្ល៉េះ ។ ដូចនៅប្រទេសឥណ្ឌាបុរាណដែរ គេជឿជាក់ថា ព្រះមហាក្សត្រជាស្តេចចក្រពត្តិ ជាអ្នកគ្រប់គ្រងដ៏ខ្ពង់ខ្ពស់ ដែលកម្ម (អំពើ) ផ្ទាល់ព្រះអង្គរបស់ទ្រង់ ដើរតួនាទីជាឧបករណ៍វាស់កម្រិតសីលធម៌ (ភាពរីកចម្រើន) នៅក្នុងនគររបស់ទ្រង់ ។ ផ្ទុយមកវិញ ស្ថានភាពនៅក្នុងនគរក៏បានឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈរបស់ព្រះអង្គវិញផងដែរ ។ ដូច្នេះហើយ ព្រះមហាក្សត្រ ដែលប្រព្រឹត្តត្រឹមត្រូវ អាចធានាបាននូវសន្តិភាព និងការរីកចម្រើនសម្រាប់ប្រជានុរាស្ត្ររបស់ព្រះអង្គ[៣] ។ ប៉ុន្តែ មុននឹងក្លាយទៅជាព្រះមហាក្សត្របាន លុះត្រាតែទទួលបាននូវការគាំទ្រជាផ្លូវការពីពួកព្រាហ្មណ៍បុរោហិត ដែលតាមរយៈការធ្វើពិធីបុណ្យសាសនា នឹងធ្វើឲ្យប្រជានុរាស្ត្រទាំងឡាយដឹងថា ទ្រង់គឺជាអ្នកដែលអាចភ្ជាប់ទំនាក់ទំនងរវាងទេវស្ថាន និងផ្ទៃក្រោម (ផែនដី) បាន ។ ជាមួយនឹងការដើរតួជាអ្នកតំណាងនៃធម៌ ឬតាមរយៈការធ្វើអំពើល្អ តួនាទីនៃព្រះមហាក្សត្រ គឺ ត្រូវធ្វើធម៌ឲ្យមានរបៀបរៀបរយនៅក្នុងនគរតាមរយៈការតែងតាំងមន្ត្រីរាជការ ការរៀបចំតុលាការ និងការការពារព្រះនគរផងដែរ ។

ខណៈដែលព្រះពុទ្ធសាសនាបានទទួលប្រជាប្រិយភាពនៅក្នុងចំណោមក្រុមវរជនខ្មែរហើយនោះ ព្រះមហាក្សត្រ ដែលជាស្តេចចក្រពត្តិ បានបន្ថែមនូវព្រះនាមមួយទៀតថា «ព្រះពោធិសត្វ» ដែលជាអ្នកត្រាស់ដឹងជាព្រះពុទ្ធនាពេលអនាគត ឬចាត់ទុកជាបុគ្គលដែលបានបំពេញកុសលគ្រប់គ្រាន់ដើម្បីសម្រេចបាននូវការត្រាស់ដឹង ហើយអាចរួចផុតពីវដ្តសង្សារបាន ។ នៅប្រទេសកម្ពុជាក្នុងសម័យកណ្តាល ព្រះធម៌ គឺជា «ពាក្យឱវាទរបស់ព្រះពុទ្ធ» និងជាក្បួនសីលធម៌ ឬក៏ជាអំពើសីលធម៌របស់បុគ្គលម្នាក់ៗ ដែលប្រព្រឹត្តអំពើល្អ[៤] ។ អត្ថបទជាច្រើន ដែលគេស្គាល់ថា ជាច្បាប់ទូន្មាន ដែលបានតែងឡើងនៅសម័យកណ្តាល បានរៀបរាប់អំពីអំពើល្អតាមរយៈតួនាទីជាគំរូរបស់បុគ្គលណាមួយនៅក្នុងសង្គមជាតិ ។ ជាឧទាហរណ៍ មានច្បាប់មួយបានអធិប្បាយថា ៖

រីអ្នកមានធម៌ សប្បុរសមានអាថ៌
លោកផ្ទឹមឧបមា ដូចក្លិនខ្នុរក្បែប
ក្រអែបពិសា ក្រៅក្រាស់បន្ទា
មោះក្នុងផ្អែមក្រៃ ។[៥]

ប៉ុន្តែ សម្រាប់អ្នកដែលវង្វេងចេញពីផ្លូវនៃព្រះធម៌ នឹងត្រូវបោះចូលទៅក្នុងភ្លើងនៃនិរយនរក ឬជួបនឹងសេចក្តីវេទុក្ខវេទនា[៦] ។ ម្យ៉ាងវិញទៀត ច្បាប់ជាច្រើន ក៏ទំនងបានគេសរសេរឡើងដើម្បីដាស់តឿនដល់ព្រះរាជាផងដែរ ដូចជាមាននៅក្នុងសេចក្តីដកស្រង់ខាងក្រោមនោះស្រាប់ ៖

១ (២០) បពិត្រព្រះបាទ ព្រះបរមនាថ

លើសលោកកន្ទង　　　ជាតិជាឥសូរ<br>
កំពូលរាស្ត្រផង　　　ព្រះអង្គជាច្បង<br>
ឯកឥតផ្ទឹមដល់ ។

១ (២១)　យកព្រះប្រាជ្ញា　　　យកព្រះញាណថ្វា<br>
ថ្វៃងព្រះយោបល់　　　ត្រេចត្រិះកម្រាប<br>
អ្នកបាបកំហល់　　　ឲ្យនិរព្យសន៍សល់<br>
បានដូចប្រាថ្នា ។[៧]

១ (២៣)　បពិត្រមហារាជ　　　ទ្រើសទ្រង់អំណាច<br>
ចេស្តាបុទ្ធី　　　អញ្ជើញស្តេចស្តាប់<br>
ជាច្បាប់គម្ពីរ　　　សព្វប្រវេណី<br>
ថ្កុលថ្កើងចំពោះ ។[៨]

នៅពេលដែលព្រះពុទ្ធសាសនាបានក្លាយជាសាសនារបស់ក្រុមវរជនហើយនោះ ការធ្វើឲ្យមេដឹកនាំណាម្នាក់មានអំណាចស្របច្បាប់ ដោយពិធីសាសនា ដែលពួកព្រាហ្មណ៍ធ្វើកាលពីមុននោះ ត្រូវផ្លាស់ប្តូរដោយឲ្យព្រះសង្ឃធ្វើជំនួសវិញ[៩] ដែលជាអ្នកមានសិទ្ធិអំណាចក្នុងការសម្រេចថា បុគ្គលណាមួយមានគុណសម្បត្តិគ្រប់គ្រាន់ អាចក្លាយទៅជាមេដឹកនាំបាន ។ តួនាទីរបស់ព្រះសង្ឃដូចបានរៀបរាប់មកនេះ ច្រើនកើតមានជាពិសេសនៅតាមទីជនបទ ដែលរដ្ឋបាលអំណាចកណ្តាលមិនសូវមានឥទ្ធិពលដល់ ។ ប៉ុន្តែ នៅក្នុងពេលជាមួយគ្នានោះដែរ ព្រះសង្ឃក៏ត្រូវការជំនួយពីព្រះរាជា និងក្រុមវីរជនជាន់ខ្ពស់វិញផងដែរ ក្នុងការស្ថាបនាព្រះវិហារ ការប្រគេនចង្ហាន់ ស្បង់ចីពរ សម្ភារៈផ្សេងៗទៀត ដែលចាំបាច់សម្រាប់ការបកប្រែគម្ពីរ និងក្នុងការធ្វើជាគំរូល្អ ដើម្បីលើកទឹកចិត្តដល់យុវជនក្មេងៗឲ្យចូលបួសជាសាមណេរក្នុងរយៈពេលណាមួយ ។ ជាឧទាហរណ៍ ព្រះអង្គចន្ទបានទ្រង់ស្ថាបនានូវទីតាំងសាសនាថ្មីៗ និងព្រះពុទ្ធបដិមាជាច្រើន បន្ទាប់ពីព្រះអង្គបានបណ្តេញក្រុមប្រឆាំងនិងឡើងសោយរាជ្យរួចមកហើយនោះ ។ ចំណេះដឹងខាងនយោបាយរបស់ព្រះអង្គ បានសន្មតនៅក្នុងការកត់ត្រាថា បានមកដោយសារតែការមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា និងការប្រតិបត្តិព្រះធម៌[១០] ។ ដូច្នេះហើយ ព្រះរាជាដែលជាពុទ្ធសាសនិក ត្រូវទទួលរ៉ាប់រងក្នុងការថែរក្សានូវកុសលធម៌កម្រិតខ្ពស់ តាមរយៈការធ្វើឲ្យសម្រេចនូវសកម្មភាពប្រកបដោយជំនឿមុតមាំ ដែលអាចឆ្លុះបញ្ចាំងមកវិញនូវកម្រិតនៃកុសលធម៌ សម្រាប់ព្រះរាជាណាចក្រ ។ ផ្ទុយទៅវិញ ប្រសិនបើព្រះអង្គមិនប្រព្រឹត្តតាមធម៌នោះ អាចនឹងមានផលវិបាកលើកម្រិតនៃកុសលរបស់ព្រះរាជាណាចក្រ ឯការថែរក្សានូវធម្មចក្រ ដោយធ្វើការកែប្រែជនណាដែលបានប្រព្រឹត្តប្រាសចាកពីទង្វើល្អ តាមរយៈការដាក់ទណ្ឌកម្ម និងស្តារនីតិសម្បទា[១១] ។

បើតាមន័យដើម ព្រះធម៌ ដែលមានន័យថា ធ្វើឲ្យមានសណ្តាប់ធ្នាប់នោះ គឺជាគំនិតធ្វើឲ្យមានតុល្យភាព ឬការបំពេញបង្គ្រប់នូវសេចក្តីខ្វះចន្លោះណាមួយ ។ ដូច្នេះ វាហាក់ដូចជាធ្វើឲ្យយើងអាច

សន្និដ្ឋានថា ប្រហែលជាស្ត្រីគ្រាន់តែជាអ្នកបំពេញបន្ថែមការខ្វះចន្លោះដល់ព្រះរាជាតែប៉ុណ្ណោះ បើទោះបីជាស្រីទាំងនោះ ដូចជាព្រះមហាក្សត្រីដែលមានកុសលធម៌ខ្ពង់ខ្ពស់ជាដើមនោះ ក៏មិនត្រូវចូលរួមជាដាច់ខាតនៅក្នុងការពិភាក្សាអំពីអំណាចក្នុងពុទ្ធសាសនាដែរ ។

ការសន្និដ្ឋានរបស់នាងខ្ញុំនេះ ក៏មានអំណះអំណាងនៅក្នុងអត្ថបទ ដែលហៅថា «ច្បាប់» ផងដែរ ។ ដូចនៅក្នុងករណីនៃអត្ថបទពុទ្ធសាសនាដំបូងនៅឥណ្ឌា ច្បាប់មានទស្សនៈ ២ ទៅលើស្ត្រី ដែលពេលខ្លះហាក់ដូចជាចាត់ទុកពួកគេថា ជាកម្លាំងនៃសេចក្តីល្អ ប៉ុន្តែពេលខ្លះកំណត់ថា ពួកគេ គឺជាអ្នកធ្វើឲ្យសង្គមល្អក់កករទៅវិញ ។ អ្នកស្រាវជ្រាវខ្លះបានចាត់ទុកថា ការមានចំណុចមិនស្របគ្នានៅក្នុងអក្សរសិល្ប៍ពុទ្ធសាសនាដំបូងនៅឥណ្ឌានោះ គឺដោយសារតែការខ្វែងគំនិតគ្នាចំពោះស្ត្រី[១២] ។ ប៉ុន្តែ លោក អាឡាន់ ស្ប៉ុនបឺគ បានផ្តល់យោបល់អំពីបញ្ហានេះថា អត្ថបទអក្សរសិល្ប៍ពុទ្ធសាសនាដំបូងនៅក្នុងប្រទេសឥណ្ឌា ប្រកបដោយទស្សនៈជាច្រើន ដោយទស្សនៈនីមួយៗ បានបង្ហាញនូវការខ្វល់ខ្វាយផ្សេងៗគ្នា ដែលកើតឡើងជាញឹកញាប់ នៅក្នុងចំណោមសមាជិកក្នុងសហគមន៍ដំបូង[១៣] ។ នេះក៏ជាករណីមួយផងដែរ ដែលគេបានលើកយកច្បាប់មកត្រូវពិចារណា ជាពិសេស «ច្បាប់ចាស់» ដែលគេបានសរសេរមុនចុងគ្រិស្តសតវត្សរ៍ទី ១៨ ហើយច្បាប់ដែលសរសេរឡើងក្រោយសតវត្សរ៍នេះ គេហៅថា «ច្បាប់ថ្មី» ដែលជាទូទៅ គឺបានមកពីការប្រមូលចងក្រងនូវច្បាប់មុនៗ[១៤] ។

ក្នុងច្បាប់ទាំងនោះ ក៏មានរៀបរាប់ពីបុរស និងនារីផងដែរ ឬក៏ចង្អុលបង្ហាញបន្ថែមទៀតនូវតួនាទីផ្សេងៗគ្នានៃភេទទាំងពីរ ។ ក្នុងច្បាប់មួយ មានសរសេរថា ភេទ គឺមិនសំខាន់ទេ ៖

ទោះប្រុសទោះស្រី      កើតនាលោកិយ
លោកឲ្យគាប់គ្រូ      ក្រែងមានផ្លេះផ្លាប
ស្រឡាបត្រង់ត្រូវ      ក្រែងដូពុំដូ
កាលកម្មវេរា ។[១៥]

នេះបានបង្ហាញឲ្យឃើញថា ពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជានាសម័យកណ្តាល បានឆ្លុះបញ្ចាំងនូវការប្រតិបត្តិពុទ្ធសាសនាដំបូងនៅក្នុងប្រទេសឥណ្ឌា នៅពេលគ្មានការរារាំងស្ត្រីមិនឲ្យទទួលបានអរហត្តផល[១៦] ។

ជាពិសេសទៅទៀត នៅក្នុងច្បាប់រាជនេតិ បានរៀបរាប់ថា «ទេពីមើលក្រឹត្យ ក្សត្រាមើលឫទ្ធិ» បានន័យថា អំណាចរបស់ព្រះមហេសីឬព្រះវររាជមាតា គឺស្ថិតនៅក្នុងការកសាងកុសលធម៌របស់ទ្រង់ ហើយអំណាចរបស់ព្រះមហាក្សត្រ គឺស្ថិតនៅលើកម្លាំងរេហ៍ពល កម្លាំងទ័ព[១៧] ។ ប្រសិនបើពិនិត្យទៅលើការរៀបរាប់ទាំងនេះ ការសន្និដ្ឋានមួយ (របស់ពួកលោកខាងលិច) ទាញថា ដោយសារតែស្តេចមានអំណាចទ័ព ទ្រង់ប្រាកដជាមនុស្សសំខាន់ជាងគេទាំងអស់ ។ ប៉ុន្តែ ការសន្និដ្ឋានរបៀបនេះ អាចនឹងនាំទៅរកការបញ្ចុះគុណតម្លៃដ៏សំខាន់ក្នុងការវិភាគទៅលើអំណាចអភិធម្មជាតិ ដែលបន្ថែមទៅលើការគ្រប់គ្រងលើធនធានសេដ្ឋកិច្ច និងអំណាចទ័ពនៅក្នុងប្រទេសកម្ពុជា និងតំបន់ផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍ ។ នេះមិនមែនជាករណីដែលនាងខ្ញុំយកមកសិក្សាទេ ប៉ុន្តែ ព្រះមហេសីឬព្រះវររាជមាតាទាំងឡាយ គេតម្រូវឲ្យប្រតិបត្តិនូវច្បាប់ព្រះធម៌ ស្រដៀងគ្នាទៅនឹងច្បាប់ព្រះធម៌សម្រាប់ព្រះមហាក្សត្រដែរ ។

ការធ្វើនូវអំពើជាកុសលធម៌ ដោយព្រះមហេសីឬព្រះវរាជមាតា គេបានកត់សម្គាល់ថា មានតាំងតែពីចុងសម័យអង្គរមកម្ល៉េះ (គ.ស. ៨០២-១៤៣១) ។ នៅក្នុងបសិលាចារឹកថាសរសើរព្រះនាងជ័យរាជទេវី ដែលជាអគ្គមហេសីរបស់ព្រះបាទ ជ័យវរ្ម័ន ទី ៧ (សោយរាជ្យពី គ.ស. ១១៨១ ដល់ប្រមាណ ១២១៨) មានរៀបរាប់ថា ព្រះនាងបានធ្វើនូវការគោរពបូជាជាច្រើន នៅក្នុងជីវិតរបស់ព្រះនាង រួមទាំងការសាងរូបសំណាកគ្រូសារព្រះញាតិវង្ស និងគ្រូបាអាចារ្យ ដែលបានបង្រៀនពុទ្ធសាសនាដល់ព្រះនាងទៀតផង[១៨] ។ ឯសិលាចារឹកមួយនៃសម័យកណ្តាល ចារឹកកាលពីមហាសករាជ (ម.ស.) ១៤៩៩ (ត្រូវនឹង គ.ស. ១៥៧៧) ក៏បានរំលឹកពីអំពើជាកុសលធម៌របស់ព្រះរាជមាតា ព្រះនាម មហាកល្យាណវត្តីគ្រីសុជាតា (មហាកល្យាណវតីស្រីសុជាតា) ផងដែរ ។ ដូចមាននៅក្នុងសិលាចារឹកនេះ ព្រះអង្គទ្រង់មានព្រះរាជសវនីយ៍ថា ÷ «នេះដ៏គឺត្រីពិធសុចរិតសទ្ធានៃខ្ញុំអម្ចាស់សម្តេចព្រះរាជមាតា មហាកល្យាណវតីស្រីសុជាតាឧត្តម ជាតិក្សត្រីព្រះមហាឧបាសិការ័ត្នបពិត្រ ថ្វាយបង្គំប្រណម្យទូលដំព្រះវរបាទារពិន្ទុនៃសម្តេចព្រះមហាស្រីរតនត្រ័យគម្តែងយើង ដ៏ជាពំនាក់ត្រើយត្រាណ ប្រធានរូសំពៅ [= បីដូចសំពៅ] ជារ័ត្នរុងឧត្តុង្គដ៏ជានូវនាំឆ្លងលែងសមុទ្រ ពោលមន់គឺ [=នេះគឺ] ភពជាតិកន្តារសរណា ខ្ញុំអម្ចាស់មានសទ្ធាតម្វាចិត្តប្រព្រឹត្តសាងសព្វកុសលរៀងមក លុះជាតិឥឡូវនេះ មន់គឺលុះដំ ១៤៩៩ ស័ក ឆ្លូវនក្សត្រចុត្ថុរទសីកើត [=ថ្ងៃ១៤កើត] អាសាឍ សោរពារ [=ថ្ងៃសៅរ៍] ។[១៩] » ។

មិនត្រឹមតែធ្វើនូវអំពើជាកុសល ដូចបានរៀបរាប់ខាងលើនោះទេ ព្រះនាងក៏បានជំរុញឲ្យព្រះរាជបុត្ររបស់ព្រះនាង គឺ ព្រះអង្គចន្ទ (ព្រះបាទសម្តេចព្រះបរមរាជា) ធ្វើការជួសជុលស្តានព្រះពិស្ណុលោក (ប្រាសាទអង្គរវត្ត) ថែមទៀតផង[២០] ។ ម្យ៉ាងវិញទៀត ដោយមាន «សុចរិតសទ្ធាព្ធដ៏ព្រះសាសនាព្រះតថាគតស្រគត់ជាលអនិច្ចា រំពឹងយល់នាមរូបធម៌នេះពុំទៀង សឹងដ៏ពុំជូអាត្មា [=មិនពិតអាត្មា, អនត្តា] » ព្រះនាងក៏បាន «ដាក់ [=កោរ] ព្រះកេសមោលីនាមានចេស្តា អំពល់នូវ [=មានទាំង] មុទ្ធាភិសេក» ហើយ «ដុតជាខ្ទុកសាងព្រះពុទ្ធរូបព្ធដ៏ស្តានបាកាណ» ទៀតផង[២១] ។ ចំណែកឯនៅក្នុង ម.ស. ១៦០៦ (គ.ស. ១៦៨៤) ព្រះស្នំឯករបស់ព្រះបាទ ជ័យជេដ្ឋា ទី ៣ (សោយរាជ្យ គ.ស. ១៦៧៧-១៦៩៥) ដែលបានសាងព្រះពុទ្ធរូបពីសំណខ្វះ ប្រាក់ខ្វះ មាសខ្វះ បានបញ្ជាឲ្យគេសាងពិតាន ១ ទង់ ១ និងឲ្យគេចម្លងគម្ពីរ ៥ ចប់ រួចហើយប្រគេនថ្វាយទៅកាន់វត្តមួយ ។ ព្រះស្នំឯកក៏បានវេរនូវទូ ស្បង់ គ្រឿងបាយ គ្រឿងទឹក កន្ទេល ខ្នើយ គ្រឿងស្លា កាំបិត ចប ពន្ធាក ដឹង និងអស់គ្រឿងដែក សម្រាប់ព្រះសង្ឃប្រើប្រាស់ផងដែរ ។ រាល់អំពើបុណ្យកុសលទាំងនេះ ព្រះស្នំឯកមិនបានធ្វើសម្រាប់ខ្លួនឯងនោះទេ គឺសម្រាប់ «ចម្រើនទៅព្រះរាជាធិរាជដ៏ជាស្វាមី» របស់នាងតែប៉ុណ្ណោះ[២២] ។ ចំណែកក្សត្រី និងអ្នកម្នាងផ្សេងទៀត ក៏បានប្រគេនវត្ថុផ្សេងៗ ក្នុងការកសាងព្រះវិហារនិងវត្តផងដែរ ។ ជាឧទាហរណ៍ អ្នកម្នាងអូត ដែលជាអ្នកម្នាងដំបូងរបស់ព្រះអង្គអេង (ព្រះបាទសម្តេចព្រះនារាយណ៍រាមា សោយរាជ្យ គ.ស. ១៧៧៩-១៧៩៦) គឺជាអ្នកកសាងវត្តធម្មកេរ[២៣] ។

ក៏ដូចជាព្រះមហាក្សត្រដែរ ព្រះមហេសីទាំងឡាយត្រូវបានគេតម្រូវឲ្យប្រកាន់ខ្ជាប់នូវអាកប្បកិរិយាត្រឹមត្រូវសមស្របទៅតាមឋានៈជាគំរូគេដែរ (សូមមើលរូបលេខ ១) ។ ដូច្នេះហើយ ការមានសទ្ធាចំពោះព្រះធម៌ ត្រូវតែសម្តែងឡើងទាំងនៅក្នុងជីវិតឯកជន ទាំងនៅក្នុងទីសាធារណៈ ។ ជាតួ

យ៉ាង ព្រះនាងឥន្ទ្រទេវី ដែលជាព្រះរៀមរបស់ព្រះនាងជ័យរាជទេវី បានធ្វើឲ្យព្រះនាងជ័យរាជទេវីស្ថិតនៅក្នុងភាពសុខនិងស្ងប់នៃព្រះធម៌របស់ព្រះពុទ្ធអង្គ ដែលអាចជួយនាំចាកផុតពីភ្លើងកន្លល់បាន[២៤] ។ ក្រោយមក ព្រះនាងជ័យរាជទេវីបានតាំងពិធីយ៉ាងជោគជ័យ ដោយធ្វើសមាធិ ដែលមានព្រះពុទ្ធរូបជាកសិណ ។ ជាលទ្ធផល ព្រះនាងមានលទ្ធភាពអាចយល់ព្រះស្វាមីរបស់ព្រះនាងឃើញនៅក្នុងប្រទេសចម្ប៉ានាពេលនោះ ដែលដូចគ្នាទៅនឹងព្រះរាជមាតា មហាកល្យាណវតីស្រីសុជាតាដែរ ដែលបាន «រំពឹងយល់» ពីភាពមិនទៀងនៃជីវិតសត្វលោក មុនពេលធ្វើពិធីបូជាព្រះកេសារបស់ព្រះនាង[២៥] ។



រូបលេខ ១ ៖ ស្ត្រីក្នុងព្រះរាជវាំងនៅប្រទេសកម្ពុជានាសម័យកណ្តាល ។

ការប្រកាន់ខ្ជាប់នូវសីលធម៌នោះ ក៏ត្រូវបានចាត់ទុកថា មានសារៈសំខាន់បំផុតចំពោះការប្រតិបត្តិធម៌ផ្ទាល់ខ្លួនផងដែរ ។ យោងទៅតាមច្បាប់ប្រៀនប្រដៅស្ត្រីណាដែលបាត់បង់នូវគុណធម៌របស់ខ្លួន (ខាតលក្ខណ៍) ស្ត្រីនោះនឹងមិនអាចតាមគន្លងព្រះពុទ្ធសាសនាបានទេ[២៦] ។ ឧទាហរណ៍មួយទៀតក៏មានអត្ថន័យប្រហាក់ប្រហែលគ្នានេះដែរ គឺ ៖

មួយសោតជាសង្ឃ នោះឲ្យផ្គត់ផ្គង់
តាមព្រះវិន័យ ជាស្រីសោតផ្គត់
មារយាទប្រពៃ ជាមនុស្សស្រពូថ្ងៃ
ឲ្យវៀរបាបបង់ ។[២៧]

ប៉ុន្តែ មហេសីនិងព្រះរាជបុត្រីមួយចំនួន ហាក់ដូចជាបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ចាស់ជាញឹកញាប់ ។ នៅក្នុងពង្សាវតារមួយ បានរៀបរាប់ថា ព្រះភគវតីអគ្គចូវ ដែលជាព្រះអគ្គមហេសីរបស់ព្រះជ័យជេដ្ឋា ទី ២ (សោយរាជ្យ គ.ស. ១៦១៨-១៦២៧) បានលេបនូវថ្នាំសម្រើបតណ្ហាដែលព្រះស្វាមីព្រះនាងបានបញ្ជាឲ្យធ្វើ ។ នៅពេលដែលព្រះនាងសោយហើយនោះ ព្រះនាងកើតតម្រេកត្រេកត្រអាលពន់ប្រមាណ «ទ្រង់ឲ្យរើសប្រុសៗ ចូលវេនជាអចិន្ត្រៃយ៍» ក៏នៅតែពុំទាន់ស្កប់ព្រះហឫទ័យសោះ ។ ទ្រង់ចេះតែរសាប់រសល់ដោយកាមរាគ[២៨] ។ ចំណែកឯព្រះនាងម៉ែយួវត្តី (ឬសម្តេចព្រះម៉ែយួចន្ទវតី) ដែលជាព្រះរាជបុត្រីនៃព្រះបាទព្រះជ័យជេដ្ឋា ទី ២ ក៏បានផិតព្រះស្វាមីរបស់ព្រះនាង គឺ សម្តេចព្រះឧភយោរាជ (ស្រម្តេចព្រះឧទ័យបរមរាជា) ជាមួយនឹងអតីតគូកំណាន់ព្រះទ័យរបស់ព្រះ

នាង គឺ ព្រះបាទសម្តេចព្រះស្រីធម្មរាជា ទី ១ ជាស្តេចទ្រង់រាជ្យ (សោយរាជ្យ គ.ស. ១៦២៧-១៦៣២) នៅទីក្រុងឧដុង្គផងដែរ ។ ព្រះស្រីធម្មរាជា និងព្រះនាងម៉ែយួវត្តី ជាបងប្អូនគ្នា ព្រះមាតាទីទៃ ។ អំពើប្រាសចាកពីសីលធម៌នេះ ត្រូវបានគេដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ។ ព្រះបាទសម្តេចព្រះស្រីធម្មរាជា ត្រូវគេធ្វើគត់ ចំណែកព្រះម៉ែយួវត្តីត្រូវទាហានព័រទុយហ្គេនាំយកទៅឲ្យព្រះស្វាមីរបស់ព្រះនាងវិញដែរ ។ នៅទីនោះ ពួកឧកញ៉ាបានប្រឹក្សាទៅ ឃើញថា ត្រូវទោសដល់ជីវិត ។ ព្រះនាងបានទទួលទណ្ឌកម្មដោយត្រូវគេវាយនឹងដំបងទាល់តែស្លាប់ ចំពោះកំហុសដែលបានបំពានលើការប្រតិបត្តិធម៌របស់ព្រះនាង[២៩] ។

ប៉ុន្តែ ចំពោះប្រុសៗវិញ ក៏ត្រូវបានព្រមានចំពោះអំពើជាអកុសលធម៌នេះដែរ ។ ច្បាប់មួយបានប្រដៅថា កុំឲ្យសេពគប់និងស្និទ្ធស្នាលជាមួយពួកស្រីៗ[៣០] ។ ច្បាប់នេះ ប្រហែលជាព្រះបាទសម្តេចព្រះស្រីធម្មរាជា ដែលបានទ្រង់និពន្ធ ។ តាមព្រះរាជពង្សាវតារ ដល់វេលាដែលទាហានព័រទុយហ្គេដែលស៊ីឈ្នួលច្បាំងសម្រាប់ព្រះបិតុលារបស់ព្រះអង្គ គឺ ព្រះឧភយោរាជ ជិតនឹងចាប់ព្រះអង្គ ទ្រង់កាត់យកកំពូលស្លឹកត្នោតមកចារជាច្បាប់ថា ៖ «សាធុសម្ងាយ កុំបីវាយមាយ នឹងក្តីកាមាតែងឲ្យវង្វេង ក្នុងវដ្តសង្សារ ស្លាប់ទៅកាលណា សេពសោយតែទុក្ខ ។ ហេតុតែក្សត្រី នាំឲ្យអប្រិយដូចត្រីក្នុងភក់ បើជាជនផង ចង់ធ្វងនរក កុំធ្វើវិវក់ ដូចអញនេះណា ។ ពីព្រោះកាមេ ឥឡូវទាល់តែក្សិណក្ស័យជីវ៉ា ស៊ូស្លាប់ទៅគាប់ មិនផ្តាច់ធម៌អាថ៌ សូមអស់ទេវតា ជួយជាពេជញាណ [សាក្សី] ។ [...][៣១] ។ ដូច្នេះហើយ ការប្រតិបត្តិធម៌ផ្ទាល់ខ្លួន គឺជាការប្រតិបត្តិទូទៅសម្រាប់ទាំងព្រះរាជា និងទាំងព្រះមហេសីនៅក្នុងសម័យកណ្តាល ។ ប៉ុន្តែ ក៏មានភស្តុតាងជាច្រើនទៀត ដែលរៀបរាប់ថា ព្រះមហេសីជាឧបាសិកា បានប្រតិបត្តិធម៌តាមធម៌អាណាចក្រផងដែរ ដោយដឹកនាំអ្នកដែលគ្មានផ្ទះសម្បែង រស់នៅតាមផ្លូវ ឲ្យប្រែក្លាយជាមនុស្សល្អវិញ ។ ជាឧទាហរណ៍ ព្រះនាងជ័យរាជទេវី បានប្រមូលក្រុមក្រមុំដែលឪពុកម្តាយពួកគេបោះបង់ចោល មកធ្វើជាបុត្រីរបស់ព្រះនាង ហើយបានបំបួសពួកគេ ដោយប្រទាននូវសម្លៀកបំពាក់ និងទេយ្យទានផ្សេងៗ ទៅតាមបទបញ្ញត្តិនៃពិធីបុណ្យសាសនា[៣២] ។ ព្រះនាងក៏បានរៀបចំឲ្យពួកគេទាំងនោះ សម្តែងនូវរឿងល្ខោនជាច្រើនដែលព្រះនាងបានដកស្រង់ចេញពីរឿងជាតក ដើម្បីជាមធ្យោបាយក្នុងការប្រៀនប្រដៅអ្នកផង[៣៣] ។ ឯសម្តេចព្រះមហាទេវីក្សត្រី ដែលជាអគ្គមហេសីរបស់ព្រះបាទ បរមរាជា ទី ១ (សោយរាជ្យ គ.ស. ១៥៥៦-១៥៧០) បានគិតពីដករាជសម្បត្តិពីព្រះនត្តា (ចៅ) គឺ សម្តេចព្រះកែវហ្វ៉ាពញាញោម ដែលបានឡើងសោយរាជ្យ ដោយហេតុតែព្រះអង្គពុំបានគោរពតាមច្បាប់ទសពិធរាជធម៌ ។ ព្រះនាងបានត្អូញត្អែរត្រង់រឿងថា «ព្រះរាជនត្តាពុំគិតរាជការផែនដី លះសុចរិតយុត្តិធម៌ ទ្រង់ទរមាន [ទូន្មាន] ពុំជឿតាម ក្នុងនគររឹតតែមានវិបរិត កំរើបចោរប្លន់ចាក់កាប់សម្លាប់ចាប់កូនក្រមុំ [...] ឥតមានអ្នកឯណាប្រាបប្រាមគ្មាន»[៣៤] ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអស់សេនាបតីមន្ត្រីទាំងពួង រួចមកព្រះមហាទេវីក្សត្រី ក៏បានផ្ញើសុភអក្សរទៅព្រះចៅសៀម ដើម្បីសុំឲ្យបញ្ជូនសម្តេចព្រះស្រីសុរិយោពណ៌ (សុរិយោពម៌) ជាព្រះបុត្រាទី ២ នៃព្រះស្វាមីព្រះនាង វិលត្រឡប់មកប្រទេសខ្មែរវិញ ពីព្រោះទ្រង់អាចនឹងក្លាយទៅជាស្តេចល្អជាងព្រះនត្តារបស់ព្រះនាង[៣៥] ។ ស្តេចសៀមក៏បានយល់ព្រមឲ្យព្រះស្រីសុរិយោពណ៌យាងមកស្រុកខ្មែរវិញ និងបញ្ចុះបញ្ចូលប្រជានុរាស្ត្រ ។ រួចព្រះស្រីសុរិយោពណ៌

*បានប្រើទូតមកគាល់ព្រះនាងទេវីក្សត្រី ដើម្បីទូលអំពីការទទួលបាននូវជោគជ័យរបស់ព្រះអង្គ ។ ភ្លាមៗ នោះ «[សម្ដេចព្រះមហាទេវីក្សត្រី] ប្រជុំមន្ត្រីធំតូចទាំងប៉ុន្មានមកជួបជុំ ហើយស្ដេចបន្ទត សម្ដេចព្រះកែវហ្វាពីគ្រងរាជ្យចេញ» ហើយ «សម្ដេចព្រះទេវីក្សត្រី នូវព្រះរាជវង្សានុវង្សទាំងពួង ជំនុំព្រមថ្វាយរាជសម្បត្តិទៅសម្ដេចព្រះស្រីសុរិយោពណ៌» ដែលបានទទួលព្រះបរមនាមជា ព្រះបរមរាជាធិរាជ (ព្រះបរមរាជា ទី ៤ សោយរាជ្យ គ.ស. ១៦០៣-១៦១៨)*(៣៦) *។ ចំណែកឯឆ្នាំ ១៦៥៩ សម្ដេចព្រះទាវធីតា (ព្រះភគវតីអង្គចូវ) ដែលធ្លាប់ជាព្រះអគ្គមហេសីរបស់ព្រះបាទជ័យជេដ្ឋា ទី ២ (គ.ស. ១៦១៨-១៦២៧) ហើយ «មានបុណ្យពិសេសណាស់ ដោយអំណាចព្រះបុត្រីយួន និងអំណាចជាសម្ដេចព្រះទាវផង» នោះ*(៣៧) *(ជាការបង្ហាញឲ្យឃើញពីជំនឿទូទៅទៅលើអំណាចមហេសី) បានសុំជំនួយទ័ពយួនមកជួយក្សត្រខ្មែរ ២ ព្រះអង្គដើម្បីដណ្ដើមរាជ្យពីស្ដេចរាមាធិបតី ទី ១ ដែលចូលសាសនាអ៊ិស្លាម (ព្រះរាមាចូលសាសន៍)*(៣៨) *។*

*អំពើកុសលធម៌ ដែលឧបាសិកាជាច្រើនបានធ្វើឡើងនោះ គឺជាការធ្វើត្រាប់តាមព្រះមហេសីទាំងឡាយរបស់ពួកគេផងដែរ ក្នុងនោះមាននាងមាលិនីរតនាលក្ខី ដែលមានកាតព្វកិច្ចក្នុងការថែរក្សាព្រះរាជអលង្ការនៅក្នុងព្រះបរមរាជវាំងនៃព្រះបាទ ស្រិន្ទ្រវរ្ម័ន ។ គេរៀបរាប់អំពីនាងថា ជាឧបាសិកាដ៏ល្អ ជាអ្នកដែលសម្បូរទៅដោយសទ្ធាជ្រះថ្លា ទាំងផ្លូវកាយ និងផ្លូវចិត្ត បានផ្ដល់ទេយ្យទាន និងមានគុណធម៌ជាច្រើន ។ នាងជាម្ចាស់បុណ្យក្នុងការកសាងវិហារថ្មី ១ និងការជីកប្រឡាយទឹក ១ និងស្រះ ១ ហើយនៅក្នុង គ.ស. ១៣០៩ នាងបានសាងព្រះពុទ្ធរូប ១ ព្រះអង្គ និងយកពួកខ្ញុំ និងទ្រព្យសម្បត្តិផ្សេងៗ ធ្វើជាទាន និងទេយ្យទានជាច្រើនទៀតក្នុងគោលបំណងឧទ្ទិសរាល់បុណ្យកុសលទាំងនោះទៅដល់ព្រះមហាក្សត្រ*(៣៩) *។ ឯសិលាចារឹកដទៃទៀត ក៏បានរៀបរាប់អំពីឧបាសិកាជាច្រើន ដែលមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនាយ៉ាងជ្រាលជ្រៅដែរ ដោយបានប្រោសខ្ញុំ (ទាសាទាសី) ជាច្រើនដើម្បីឲ្យបានទទួលកុសលផលបុណ្យ*(៤០) *ហើយបើតាមព្រះរាជពង្សាវតារវិញ បានរៀបរាប់ថា ទីក្រុងភ្នំពេញបានបង្កើតឡើង ក៏ដោយសារតែលទ្ធផលនៃការគោរពបូជាព្រះពុទ្ធសាសនារបស់ដូនពេញដែរ ។ កាលនោះ ដូនពេញបានរស់នៅលើឆ្នេរទន្លេដែលប្រសព្វគ្នា រវាងទន្លេបាសាក់និងទន្លេសាប ។ ថ្ងៃមួយ បន្ទាប់ពីមានទឹកជំនន់មក ដូនពេញបានឃើញព្រះពុទ្ធរូប ៤ ព្រះអង្គ និងរូបព្រះនារាយណ៍ ១ ព្រះអង្គនៅក្នុងដើមគគីរ ។ ដូនពេញបាននាំរូបចម្លាក់ទាំងនោះមកផ្ទះ រួចហើយប្រមូលអ្នកស្រុកឲ្យជួយពូនដីធ្វើជាភ្នំតូចមួយនៅជិតផ្ទះ ដើម្បីកសាងព្រះវិហារនៅលើភ្នំនោះ ។ ដូនពេញបានតម្កល់ព្រះពុទ្ធរូបទាំងបួនព្រះអង្គ នៅក្នុងព្រះវិហារ ហើយតម្កល់រូបព្រះនារាយណ៍នៅជើងភ្នំទិសខាងកើត ព្រមទាំងនិមន្តព្រះសង្ឃឲ្យមកគង់នៅក្នុងវត្តមួយ ដែលកសាងទល់មុខនឹងភ្នំនោះ*(៤១) *។ ដើម្បីដឹងគុណដូនពេញ ទើបគេកសាងរូបចម្លាក់តាងដូនពេញនៅលើភ្នំនោះ ហើយគេតែងតែធ្វើសក្ការបូជាដល់រូបមេពេញនោះជានិច្ចរហូតមកដល់សព្វថ្ងៃនេះ* (រូបលេខ ២) *។*

*ឧទាហរណ៍មួយទៀត គឺ៖ «ត្បិតនាងហៀមមកគិតនឹងសាងកុសលផលបុណ្យនោះ» ក៏បានអារាធនានិមន្តព្រះសង្ឃឲ្យទៅសូត្រមន្តនៅលើព្រះពាន់ឯអង្គរវត្ត ហើយបានប្រគេនដល់ព្រះសង្ឃរួមទាំងមហាសង្ឃរាជផង នូវព្រះពុទ្ធរូប និងរបស់របរផ្សេងៗ ជាច្រើនទៀត*(៤២) *។ ឯចំណែកនាងបែនវិញ បានធ្វើនូវអំពើកុសលតាំងពីអាយុ ១៦ ឆ្នាំរហូតដល់ពេលអាយុ ៤៤ ឆ្នាំ ដោយបានសាងព្រះ*

ពុទ្ធរូប ១៧ អង្គ ព្រះបត់ ១ ទង់ ៩ ពិតាន ៣ ក្ញស់ ១ សាងភ្នំ ១០០០ ពីរដង បំបួសកូន ៩ ដង សាងគម្ពីរ ៥ ចប់ ប្តូងត្រៃចីវរ ៥ វត្តពន្ធ ៤០ សាងក្ញីវន្ទា[៤៣] ។ ប្តីប្រពន្ធជាច្រើន ក៏បានធ្វើអំពើកុសលរួមគ្នាជាច្រើនដែរ ដូចជា ព្រះពិជ័យនាគ និងអ្នកម៉ែបាន បានកសាងវត្តអារាមមួយសម្រាប់ព្រះសង្ឃមកគង់ ដែលគេនាំគ្នាហៅទៅតាមឈ្មោះអ្នកម៉ែបាន ថា វត្តម៉ែបាន ឬ វត្តមេបាន[៤៤] ។ អកហ្លួងអភ័យរាជ និងប្រពន្ធរបស់លោក គឺ អ្នកអកធម៌ មានចិត្តសទ្ធាសាងព្រះវិហារមួយនៅ ម.ស. ១៤៨៨ (គ.ស. ១៥៦៦) ហើយថែមទាំងសាងព្រះពុទ្ធរូបមាស ១ អង្គ ព្រះថ្ម ៥ អង្គ ព្រះប្រាក់ ១ អង្គ សាង (ដួសដុល) ចេតិយ ដែលបាក់បែក ១ ដាំដើមពោធិ៍មួយចំនួន ហើយនិងឲ្យគេចម្លងគម្ពីរជាច្រើនច្បាប់[៤៥] ។


រូបលេខ ២ ៖ រូបសំណាកមេពេញ ។

ឧបាសិកាជាច្រើន ក៏បានយកគំរូតាមព្រះមហេសីរបស់ពួកគេផងដែរ ក្នុងការប្រតិបត្តិនូវធម៌ផ្ទាល់ខ្លួន ។ ជាឧទាហរណ៍ ព្រះមហេសីមួយព្រះអង្គនៅគ្រិស្តសតវត្សរ៍ទី ១៣ ព្រះនាម ឥន្ទ្រទេវី បានទទួលតំណែងជាចាងហ្វាងមហាវិទ្យាល័យបី គឺ នគេន្ទ្រតុង្គ ១ តិលកោត្តរ ១ និង នរេន្ទ្រាស្រម ១ ដែលបានបង្រៀននូវលទ្ធិពុទ្ធសាសនា និង «សាស្ត្រ» ដទៃទៀត ។ ក្នុងចំណោមនោះ មហាវិទ្យាល័យនរេន្ទ្រាស្រម ប្រហែលជាផ្តល់ការអប់រំដល់ស្ត្រីទាំងឡាយ ទាំងអ្នកដែលមកពីគ្រួសារពាស្ត្រសាមញ្ញ និងពួកអភិជន[៤៦] ។ ចំណែកឯនាងមធ្យទេសា ដែលជាអ្នករៀបផ្កានៅក្នុងព្រះបរមរាជវាំងខ្មែរនៅក្នុង ស.វ. ទី ១៤ បានខំប្រឹងប្រតិបត្តិតួនាទីរបស់នាងយ៉ាងផ្ចិតផ្ចង់ ព្រោះតែមានសេចក្តីភ័យខ្លាចនូវសមុទ្រនៃវដ្តសង្សារ ដូច្នេះហើយទើបនាងពុំដែលបានធ្វើអ្វីឲ្យខុសក្នុងការបំពេញភារកិច្ចរបស់នាងឡើយ[៤៧] ។ ស្ត្រីខ្លះទៀត ហាក់ដូចជាមានស្មារតីមុតមាំក្នុងការជឿលើព្រះពុទ្ធសាសនា ។ ជាឧទាហរណ៍ នៅក្នុងព្រះរាជពង្សាវតារ គេបានរៀបរាប់ថា អ្នកម៉ែបាន ជាពលព្រះស្រីរតនត្រ័យ (គឺ ពលដែលមានមុខងារជាអ្នកថែរក្សាវត្តអារាម)[៤៨] ។ ឯជំទាវស្រីកញ្ញាកេសរ បានធ្វើអំពើកុសលបុណ្យជាច្រើន ដើម្បីឧទ្ទិសឲ្យទៅប្តី (ឧកញ៉ាសេនាបរទេស) ដែលខូចទៅហើយ ហើយគាត់បានថ្លែងថា ៖ «**ភន្តេភគវា** បពិត្រព្រះដ៏មានបុណ្យ ហេតុតេជតេជះតបះខ្ញុំមានចិត្តកាត់តម្វាសទ្ធាធ្វើអំពើកុសលផលបុណ្យអស់ទាំងអំបាលនេះ សំណេះដូនទៅឧកញ៉ាសេនាបរទេស សូមឲ្យវិសេសដូចប្រាថ្នា បានប្រសព្វនឹងគ្នាសព្វៗ ជាតិកំណើត ដរាបលុះបានដល់ប្រាជ្ញាអរហត្តបដិសម្ភិទាញាណ បានចូលនិព្វានជាបង្អស់ហោង»[៤៩] ។

អាកប្បកិរិយាប្រកាន់ខ្ជាប់នូវសីលធម៌ ដែលមហាក្សត្រីជាច្រើនបានប្រតិបត្តិនោះ ក៏ត្រូវបានប្រតិបត្តិដោយស្រីទាំងឡាយផ្សេងទៀតផងដែរ ។ ជាឧទាហរណ៍ មានស្តេចមួយអង្គ ព្រះនាម បរមរាជា ទី ៣

(សោយរាជ្យ គ.ស. ១៥៩៩-១៦០០) បានព្យាយាមលួងលោមស្រីម្នាក់ ដែលជាប្រពន្ធអ្នកដទៃ ដោយសន្យាផ្តល់ឲ្យនាងនូវទ្រព្យសម្បត្តិ និងឋានៈខ្ពង់ខ្ពស់ ។ នៅពេលដែលការលួងលោមនោះមិនបានសម្រេច ទ្រង់ក៏បានប្រើកម្លាំងបាយបង្ខំវិញ ប៉ុន្តែ ស្ត្រីនោះនៅតែប្រឆាំងដាច់ខាតចំពោះទ្រង់ ដោយគិតថា ស្ត្រីម្នាក់ដែលមានប្តីពីរបីនោះនឹងមិនសមរម្យទេ ឬនាងនឹងក្លាយទៅជាស្រីដែលពុំមានគុណធម៌ ពុំមានសេចក្តីស្មោះត្រង់ និងដឹងគុណចំពោះប្តីរបស់នាង ប្រសិនបើនាងព្រមធ្វើតាមព្រះរាជានោះ[៥០] ។

នៅក្នុងប្រទេសកម្ពុជាសម័យកណ្តាល យើងអាចបែងចែកតួនាទីរបស់ឧបាសិកា ជា ២ ប្រភេទ គឺជាដូនជី និងជាម្តាយ ។ នៅចុង ស.វ. ទី ១៣ អ្នកសង្កេតការណ៍ជនជាតិចិនម្នាក់ បានកត់សម្គាល់ឃើញថា ពុំមានដូនជីនៅក្នុងរាជធានីខ្មែរទេ[៥១] ។ ប៉ុន្តែ នៅក្រុងស្រីអយុធ្យា ស្រីដែលមានឋានៈខ្ពង់ខ្ពស់ គឺជាប្រមុខសាសនា[៥២] ហើយពង្សាវតារសៀមបាននិយាយអំពី «អ្នកជី» ១ នាក់ ដែលជាដូនជីពុទ្ធសាសនានៅក្នុងរាជវាំងសៀម ដែលមានដើមកំណើតមកពីប្រទេសខ្មែរ[៥៣] ។ ចំណែកឯសិលាចារឹកជាច្រើន ក៏បានចង្អុលបង្ហាញថា មានស្ត្រីជាច្រើនក្នុងចំណោមពុទ្ធសាសនិកទាំងឡាយ ត្រូវបានគេទទួលស្គាល់ថា ជាឧបាសិកា ដែលមានសទ្ធាជ្រះថ្លាខ្ពង់ខ្ពស់ដែរ[៥៤] ។ ដូនជីមានវត្តមាន ពាសពេញតំបន់អាស៊ីអាគ្នេយ៍ក្នុងអំឡុងពេលដំបូងនៃសម័យទំនើប ដោយបំពេញតួនាទីជាអ្នកបង្រៀន ជាអ្នកចម្រើនសមាធិ និងចូលរួមក្នុងពិធីបុណ្យនៅតាមវត្តនានា[៥៥] ។ មានការលើកឡើងនូវតួនាទីរបស់ស្ត្រីដែលមានឋានៈខ្ពង់ខ្ពស់ជាច្រើននៅក្នុងសិលាចារឹកសម័យកណ្តាល ដែលបានចូលរួមចំណែក ធ្វើឲ្យវត្តមានការរីកចម្រើនទៅតាមសមត្ថភាពរបស់ពួកគេរៀងៗខ្លួន ។

នៅក្នុងពេលមួយ បន្ទាប់ពីឆ្នាំ ១៧៤៧ ឧកញ៉ា ១ នាក់ និងភរិយារបស់លោក ព្រមទាំងម្តាយមីងបង្កើត ១ នាក់ ខ្ញែ (ប្អូនប្ងបង្ងៃ) ១ នាក់ និង ក្មួយស្រី ២ នាក់ទៀត បានធ្វើដំណើរទៅប្រាសាទអង្គរវត្ត ដើម្បីប្រគេនទេយ្យវត្ថុដល់ព្រះសង្ឃ ។ បន្ទាប់មកទៀត ក្រៅពីអ្នកឧកញ៉ាចេញ ស្ត្រីទាំងឡាយដែលទៅជាមួយលោក បានបួសជា «នាងជី»[៥៦] ។ ដូច្នេះ យើងឃើញថា មានទំនាក់ទំនងគ្នាយ៉ាងច្បាស់រវាងការបួសជា «នាងជី» និងការបួសជា «កន្លែកក្លាញ» នៅក្នុងសម័យមុនៗ[៥៧] ហើយនេះក៏ជាហេតុដែលបញ្ជាក់ផងដែរថា ការចូលបួស បើទោះបីជានៅក្នុងអំឡុងពេលបណ្តោះអាសន្នក៏ដោយ ក៏ជាការធ្វើបុណ្យកុសលយ៉ាងធំមួយ ដើម្បីឧទ្ទិសទៅដល់នរណាម្នាក់ ឬឲ្យបានសម្រេចការងារអ្វីមួយផងដែរ ។

ទំនាក់ទំនងជាពិសេសរវាងម្តាយនិងសាមណេរ ក៏បានឆ្លុះបញ្ចាំងនៅក្នុងទំនៀមទម្លាប់បំបួសកូនចិញ្ចឹមរបស់ខ្លួនផងដែរ ។ ជាឧទាហរណ៍ មានមនុស្ស ៦ នាក់ គឺ ស្រី ៣ និងប្រុស ៣ មានចិត្តសទ្ធាសាងព្រះពុទ្ធរូបមាស ១ ព្រះអង្គ ព្រះពុទ្ធរូបប្រាក់ ៣ ព្រះអង្គ និងទង់ ១ ។ បន្ទាប់មកទៀត «អ្នកទាំង ៦ នេះ មានមេត្តាករុណាព្រមជាមួយ ហើយមកបំបួសជី អ៊ូ នេះឲ្យរួចជាព័ណ៌ស្រមជ្រះស្រឡះឥតកំដឹងឡើយ រីឯមេកែវនេះ យកជីអ៊ូនេះជាកូនកើតក្នុងឧទរដូចចៅប្រាប មេធានឯងហោង[៥៨] » ។ ដូច្នេះហើយ ទង្វើទាំងនេះមិនមែនត្រឹមតែជាអំពើដែលនាំឲ្យបានទទួលបុណ្យកុសលច្រើនក្នុងការប្រោសនោះទេ ប៉ុន្តែ ថែមទាំងបង្ហាញថា ការបំបួសកូន ក៏ជាពិធីមួយដែលផ្តល់នូវបុណ្យកុសលជាច្រើនដល់ម្តាយចិញ្ចឹមផងដែរ[៥៩] ។ ដប់មួយឆ្នាំក្រោយមក ស្រីដដែលនោះ (មេកែវ) បានធ្វើដំណើរឆ្លងទន្លេសាបជាមួយក្រុមគ្រួសាររបស់គាត់ ដើម្បីទៅសួរសុខទុក្ខ «កូនចៅផៅព័ណ៌ញាតិកា» នៅឯមហានគរ (អង្គរ) ។ បន្ថែមពីលើការសាងនូវពុទ្ធរូប និងទង់ធម្មជ ថ្វាយទៅដល់វត្ត ពួកគាត់ក៏បានបំបួសកូន ២ នាក់ទៀត

នៅក្នុងវត្ត[៦០] ។ នៅសិលាចារឹកសម័យក្រោយអង្គរ ១ ផ្ទាំងទៀត គឺសិលាចារឹកលេខ ៣៩ ក៏បានកត់ត្រាផងដែរថា មានឧកញ៉ាម្នាក់បាន «លើកអ្នកគង់កូនប្រុសអាយុសឆ្នាំ ៨ [=**អាយុ ៨ ឆ្នាំ**] បូជាព្រះធម៌ ហើយបូជាប្រាក់បាទ ៣ [=**ប្រាក់ ៣ បាទ**] ទើបលោះតួអ្នកគង់កូនប្រុសតម្លឹង ៧ [=**៧ តម្លឹង**]» [...] «ហើយសូមបានអាយុសវែងបាន ៥០០០ វស្សា កប [=**ប្រកប**] នូវប្រាជ្ញា នូវទ្រព្យសម្បត្តិ ដូចជោតិកសេដ្ឋី ហើយសូមបានជាព្រះមហាចក្កពត្តិរាជ ស្វាយសុខក្សេមក្សាន្តសប្បាយ ដរាបលុះបានចូលនិព្វានហោង[៦១]» ។

ចំពោះម្តាយ គេផ្តល់ឲ្យនូវគុណតម្លៃជាពិសេសផងដែរ នៅក្នុងទំនាក់ទំនងជាមួយនឹងសាមណេរ ។ ដូចជានៅក្នុងច្បាប់ក្រម បានទូន្មានសាមណេរឲ្យប្រតិបត្តិទៅតាមវិន័យរបស់សង្ឃ ដូច្នេះអំពើជាកុសលនោះ នឹងបានទៅដល់គ្រូបាធ្យាយ រួមទាំងឪពុកម្តាយផងដែរ ៖

ហៃអស់សាមណេរ　　　　កុំធ្វើដែលដែរ
ត្រង់ក្តីពាយឆាយ　　　　លំអុតបម្រើ
អ្នកជាបាធ្យាយ　　　　ជូនបុណ្យទៅម្តាយ
អាពុកទីទៃ ។[៦២]

ម្យ៉ាងទៀត សាមណេរនឹងត្រូវទទួលការរិះគន់ ប្រសិនបើហ៊ាននិយាយរកហេតុផល ឬប្រឆាំងទៅនឹងគ្រូបាធ្យាយ ព្រោះលោកមានឋានៈស្មើនឹងម្តាយរបស់សាមណេរនោះ ៖

ក្តីនេះជាច្បាប់　　　　ឲ្យសាមណេរគ្រាប់
សព្វសរិលទាំងឡាយ　　　　កុំសើចតិះដៀល
អ្នកជាបាធ្យាយ　　　　អ្នកហោងស្មើម្តាយ
បង្កើតក្តីច្បាប់ ។[៦៣]

នៅក្នុងការពន្យល់អំពីពុទ្ធសាសនាទៅកាន់ស្ត្រីទាំងឡាយនៅអាស៊ីប៉ែកអាគ្នេយ៍ អ្នកស្រី បារបារ៉ា វ៉ាត់សុន អណ្តាយ៉ា បានពន្យល់ថា អ្នកប្រាជ្ញជាច្រើនបានយល់ព្រមថា វិធីបុណ្យទាំងឡាយ ដែលមានទំនាក់ទំនងជាមួយពុទ្ធសាសនាថេរវាទ បានផ្តល់ឲ្យម្តាយនូវឋានៈពិសេសមួយ[៦៤] ។ រឿងជាតកជាច្រើន បានគាំទ្រនូវការពន្យល់នេះ ។ ជាឧទាហរណ៍ នៅក្នុងរឿងនិគ្រោធមិគជាតក ព្រះពោធិសត្វដែលយោនយកកំណើតកើតជាសត្វទ្រាយ បានសុខចិត្តលះបង់ជីវិតរបស់ខ្លួន ដើម្បីជួយសង្គ្រោះទ្រាយញីមានគភ៌ ១ ក្បាល[៦៥] ។

អគ្គមហេសីទាំងឡាយនៅប្រទេសកម្ពុជានាសម័យកណ្តាល ត្រូវបានទទួលនូវកិត្តិយសក្រោយពេលសោយព្រះពិរាល័យ (ស្លាប់) ជាពិសេស ។ ជាឧទាហរណ៍ បន្ទាប់ពីមហេសីនៃសពស្តេចចក្រពត្តិ នៅក្នុងរឿងព្រេង ទ្រង់សោយព្រះពិរាល័យទៅ ព្រះរាជាដែលជាព្រះរាជបុត្រនៃព្រះនាងបានសាងព្រះមេន (ព្រះមេរុ) មួយ ដើម្បីតម្កល់ព្រះសពរបស់ព្រះនាងក្នុងរយៈពេល ៥ ថ្ងៃនៅទីនោះ ហើយបន្ទាប់ពីបូជារួច ព្រះរាជាបានយកព្រះធាតុរបស់ព្រះនាង ទៅកាន់ប្រាសាទលលៃ ហើយបញ្ចុះនៅទីនោះ[៦៦] ។ ពង្សាវតារផ្សេងមួយទៀត បានរៀបរាប់ថា «ព្រះអគ្គគិតដល់គុណសម្តេចព្រះ

មាតា» ។ ដោយមានព្រះទ័យចង់ធ្វើបុណ្យកុសលឧទ្ទិសដល់ព្រះមាតារបស់ទ្រង់ ក៏បានបញ្ជាឲ្យគេសាងព្រះពុទ្ធរូបចូលនិព្វាន ១ ព្រះអង្គ និងរូបព្រះមាតារបស់ទ្រង់ ១ ព្រះអង្គនៅលើក្ដាំរូងថែមទៀតផង ។ ព្រះនាមដែលប្រសិទ្ធិឲ្យរូបចម្លាក់របស់មាតាទ្រង់ គឺ «ស្រីគ្រប់លក្ខណ៍»[៦៧] ។ ចំណែកឯព្រះនាងទេវីក្សត្រី ដែលជាឯកអគ្គមហេសីនៃព្រះបាទ បរមរាជា ទី ១ (សោយរាជ្យ គ.ស. ១៥៥៦-ប្រមាណ ១៥៧០) ពិធីបុណ្យសពរបស់ព្រះនាង ក៏ត្រូវបានគេរៀបចំធ្វើយ៉ាងអធិកអធមដែរ ដើម្បីឲ្យសមស្របទៅតាមឋានៈរបស់ព្រះនាង ។ គេបានតម្កល់ព្រះសពរបស់ព្រះនាងទុកនៅក្នុងមេន ដែលគេប្រើប្រាស់សម្រាប់ព្រះមហាក្សត្រទៀតផង ហើយវត្តព្រះស្រីក្សត្រ ដែលដាក់ឈ្មោះតាមព្រះនាមរបស់ព្រះមហេសីទេវីក្សត្រី គេក៏បានកសាងឡើងនៅក្បែរនោះផងដែរ[៦៨] ។ ចំណែកឯការសោយព្រះពិរាល័យរបស់ព្រះនាងសោភាវត្តិ ក៏មានលក្ខណៈដូចគ្នានោះដែរ ។ ព្រះរាជបុត្រាទាំងពីររបស់ព្រះនាង បាន«ធ្វើបុណ្យព្រះមាតាតាមលំដាប់ប្រវេណីដែលព្រះអង្គគង់នៅជារាស្ត្រ»[៦៩] ។

ភាពជាក្សត្រីនៅក្នុងប្រទេសកម្ពុជាសម័យកណ្ដាល សម្គាល់ទៅលើការប្រតិបត្តិនូវអំពើល្អ ដែលបង្ហាញកក្ដីភាពចំពោះព្រះធម៌ ការប្រកាន់នូវធម៌ផ្ទាល់ខ្លួននៅក្នុងន័យនៃការសមាធិ និងការគោរពតាមព្រះពុទ្ធឱវាទ បូករួមទាំងការថែរក្សានូវចរិយាធម៌ត្រឹមត្រូវ និងការធ្វើឲ្យមានសណ្ដាប់ធ្នាប់សង្គមតាមរយៈការលុបបំបាត់ជម្ងឺសង្គម និងកែតម្រូវមនុស្សដែលភ្លាំងភ្លាត់ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់ភាពសុខសាន្តត្រាណរបស់សង្គម ។

